ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

កំពង់ឆ្នាំង, ថ្ងៃទី.....ខែ.....ឆ្នាំ.....

ក្រឡាបញ្ជី

[redacted]

សាលាដំបូងខេត្តកំពង់ឆ្នាំង

តុលាការរដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណីលេខ ៥២

ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២

សាលក្រមលេខ៖ ១៨ "ង"

ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២ ។

**ដោយមានសមាសភាព**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង

**អត្តសញ្ញាណរបស់គូភាគី៖**

**ដើមចោទឈ្មោះ** [redacted] ផុន ភេទប្រុស អាយុ៧១ឆ្នាំ មានទីលំនៅបច្ចុប្បន្ន [redacted] ។

លោក [redacted] អត្តលេខ២៤២ ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] ផុន ។

**សហចុងចម្លើយ៖**

- ឈ្មោះ [redacted] រឿន ភេទស្រី អាយុ៦៥ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។
- ឈ្មោះ [redacted] នី ភេទស្រី អាយុ៣០ឆ្នាំ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ [redacted] ។
- ឈ្មោះ [redacted] វិចិត្រ ភេទប្រុស អាយុ២៩ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។
- ឈ្មោះ [redacted] សារ៉េក ភេទប្រុស អាយុ២៥ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។
- លោក [redacted] អត្តលេខ២១៦៥T ជាមេធាវីតំណាងដោយអាណត្តិឲ្យសហចុងចម្លើយឈ្មោះ ស៊ីវ រឿន, ឈ្មោះ [redacted] នី, ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] សារ៉េក ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

កំពង់ឆ្នាំង, ថ្ងៃទី...ខែ...ឆ្នាំ...

ក្រឡាបញ្ជី

[redacted]

**ខ្លឹមសារនៃសាលក្រមដែលដើមចោទបានទាមទារ÷**

១. សុំមោឃភាពលើកំណត់ហេតុចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ។

២. សុំទទួលស្គាល់ដើមចោទឈ្មោះ [redacted] ជុន ជាម្ចាស់កម្មសិទ្ធិលើដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៤០៧០១០៩-០៣២៦ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ ដែលមានទីតាំងស្ថិតនៅភូមិគិរីអភិវឌ្ឍន៍ ឃុំឈានឡើង ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

**អង្គហេតុ និងចំណុចវិវាទ÷**

**១. ការសង្ខេបអំពីរឿងក្តី**

ភាគីដើមចោទបានអះអាងថា កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ដើមចោទឈ្មោះ ឆាយ [redacted] និងសហចុងចម្លើយឈ្មោះ [redacted] រឿន បានធ្វើកំណត់ហេតុដើម្បីបែងចែកដីកសិកម្មទំហំ១ហិចតា ដែលជាកម្មសិទ្ធិរបស់ដើមចោទឈ្មោះ [redacted] ជុន ដែលទទួលបានពីរដ្ឋនៅឆ្នាំ២០១២ នូវទំហំពាក់កណ្តាលឱ្យទៅឈ្មោះ [redacted] នី, ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] សារ៉េត លុះក្រោយមកទើបដើមចោទឈ្មោះ [redacted] ជុន បានដឹងថា មានការភ័ន្តច្រឡំចំពោះការធ្វើកំណត់ហេតុនោះ ដោយគិតថាជាការធ្វើកំណត់ហេតុដើម្បីដកប្លង់ដី ហើយការធ្វើកំណត់ហេតុនោះ គឺពុំមានអាជ្ញាធរបញ្ជាក់ដឹងឮត្រឹមត្រូវតាមច្បាប់ទេ ។

**២. ចំណុចវិវាទ៖**

ក. តើកំណត់ហេតុចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ រវាងឈ្មោះ [redacted] ជុន និងឈ្មោះ [redacted] រឿន ត្រូវបានបង្កើតឡើងដោយមានអានុភាពត្រឹមត្រូវតាមផ្លូវច្បាប់ដែរឬទេ ?

ខ. តើដើមចោទឈ្មោះ [redacted] ជុន មានចំណែកទាំងមូល ឬពាក់កណ្តាលនៅលើដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៤០៧០១០៩-០៣២៦ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ ?

**៣. ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ៖**

**ក. ការអះអាងរបស់ភាគីដើមចោទ៖**

- ដើមចោទឈ្មោះ [redacted] ជុន មានដីកសិកម្មមួយកន្លែងទំហំ០១ហិកតា ដោយដីនោះ គឺដើមចោទបានពីរដ្ឋចែកឱ្យដោយសារដើមចោទជាអ្នកឈ្លួសឆាយ ហើយចែកឱ្យតែដើមចោទតែម្នាក់ទេ ។ ចំពោះដីកសិកម្មនោះ ដើមចោទពុំធ្លាប់ប្រគល់ឱ្យកូន ឬប្រពន្ធដើមនោះទេ ហើយចំពោះកំណត់ហេតុចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ នោះ គឺដើមចោទពិតជាបានផ្តិតមេដៃមែន តែការផ្តិតនោះ គឺដើម្បីដកប្លង់កម្មសិទ្ធិ ដោយសារតែដើមចោទមិនចេះអក្សរក៏ផ្តិតទៅ ប៉ុន្តែនៅពេលផ្តិតរួចទើបគេប្រាប់ថា ដីនោះខ្លួនចែកឱ្យកូនខ្លួនពាក់កណ្តាល ។ ម្យ៉ាងទៀត កំណត់ហេតុចុះថ្ងៃ៣០ ខែតុលា ឆ្នាំ២០១៩ ធ្វើឡើងពុំត្រឹមត្រូវតាមទម្រង់យថាភូតទេ ។

**ខ. ការអះអាងរបស់ភាគីសហចុងចម្លើយ៖**

ចំពោះដីកសិកម្មនេះ គឺឈ្មោះ [redacted] រឿន និងឈ្មោះ [redacted] ជុន បានដាក់ពាក្យស្នើសុំរួមគ្នាតាមរយៈគោលនយោបាយសម្បទានសង្គមកិច្ច ដោយដាក់តែឈ្មោះ ឆាយ ជុន ទេដែលជាមេគ្រួសារ ។ ចំពោះការធ្វើកំណត់ហេតុចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩នោះ គឺមានការចូលរួមជាមួយអាជ្ញាធរភូមិឃុំគិរីអភិវឌ្ឍន៍ផងដែរ ម្យ៉ាងទៀត ភាគី



Scanned with CamScanner

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ក្រឡាបញ្ជី

ដើមចោទឈ្មោះ [redacted] ជុន គាត់ជាមនុស្សមានការយល់ដឹងផងដែរ ដូច្នេះការធ្វើកំណត់ហេតុនេះមិនមែនជាការភ័ន្តច្រឡំឡើយ ។

បានឃើញ ភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ។

**សំអាងហេតុ**

១. ចំពោះការទាមទារមោឃភាពលើកំណត់ហេតុ តុលាការយល់ឃើញថា៖ [redacted]

១.ក. ដើមចោទឈ្មោះ [redacted] ជុន បានថ្លែងការណ៍ថា៖ ចំពោះកំណត់ហេតុចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ គឺខ្លួនផ្តិតមេដៃដើម្បីដកប្លង់ដីតែប៉ុណ្ណោះ មិនមែនជាការព្រមព្រៀងប្រគល់ដីទំហំពាក់កណ្តាលឱ្យទៅឈ្មោះ [redacted] នី, ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] សារ៉ែក ឡើយ ព្រោះនៅពេលធ្វើកំណត់ហេតុនោះ ខ្លួនជាមនុស្សចាស់ ពុំចេះអក្សរ ភ្នែកមើលពុំសូវឃើញ ហើយគេប្រាប់ថា ផ្តិតមេដៃដើម្បីដកប្លង់ ។ ចំពោះលោក [redacted] ហៃ ជាមេធាវីតំណាងឱ្យដើមចោទ ក៏បានបន្ថែមទៀតថា៖ កូនក្តីខ្លួនបានផ្តិតមេដៃដោយការភ័ន្តច្រឡំ មិនដឹងថាជាកំណត់ហេតុផ្ទេរដីទំហំពាក់កណ្តាលឱ្យទៅឈ្មោះ [redacted] នី, ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] សារ៉ែក នោះទេ ហើយម្យ៉ាងទៀត ការធ្វើកំណត់ហេតុនោះ គឺពុំមានស្នាមម្រាមដៃអ្នកទទួលសិទ្ធិ និងពុំមានអាជ្ញាធរបញ្ជាក់ដឹងឮត្រឹមត្រូវជាលិខិតយថាភូតទេ ដោយមានតែមេភូមិបញ្ជាក់តែម្នាក់តែប៉ុណ្ណោះ ។ រីឯសហចុងចម្លើយឈ្មោះ [redacted] រឿន បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ការធ្វើកំណត់ហេតុនោះ គឺមានលោក [redacted] សុវណ្ណ ជាមេភូមិចូលរួម និងបានអានឱ្យលោក [redacted] ជុន ស្តាប់ផងដែរ ។ ចំណែកសហចុងចម្លើយឈ្មោះ ឈ្មោះ [redacted] នី, ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] សារ៉ែក បានថ្លែងការណ៍ថា៖ ចំពោះការធ្វើកំណត់ហេតុចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ គឺលោក [redacted] ជុន មិនបានបដិសេធអ្វីទេ ដោយពេលនោះគាត់ថា បើឱ្យកូន គឺគាត់ព្រមឱ្យ ។ ចំពោះលោក [redacted] សុជាតិ ជាមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយបានបញ្ជាក់បន្ថែមថា៖ ចំពោះកំណត់ហេតុនោះ គឺមានអាជ្ញាធរចូលរួម ហើយលោក [redacted] ជុន មានស្មារតីគ្រប់គ្រាន់ក្នុងការសម្រេចនៅពេលសម្របសម្រួលគ្នា ហើយទោះបីជានៅលើកំណត់ហេតុពុំមានស្នាមមេដៃរបស់អ្នកទទួលសិទ្ធិក៏ដោយ ក៏មានម្តាយឈ្មោះ [redacted] រឿន ជាអ្នកតំណាងដឹងឮដែរ ។

១.ខ. នាពេលទាញហេតុផលដោយផ្ទាល់មាត់ សាក្សីឈ្មោះ [redacted] សុវណ្ណ បានអះអាងថា៖ ចំពោះរឿងកំណត់ហេតុចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ នោះ គឺធ្វើឡើយក្រោយពីមានការប្រជុំដោះស្រាយដោយមានស្មៀនឃុំ សុរិយោដី និងមេភូមិ ហើយចំពោះការចុះហត្ថលេខាដឹងឮ គឺមានតែខ្លួនដែលជាមេភូមិតែម្នាក់ទេ ដោយនៅពេលនោះ ខ្លួនបានប្រាប់ទៅឈ្មោះ [redacted] ជុន ថាការធ្វើកំណត់ហេតុបែងចែកដីទៅឱ្យកូននេះ គឺដើម្បីសម្រាប់ដកប្លង់ ។

១.គ. តាមការពិនិត្យទៅលើកំណត់ហេតុចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted] ជុន និងឈ្មោះ [redacted] រឿន ឃើញថា ដើមចោទឈ្មោះ [redacted] ជុន និងសហចុងចម្លើយឈ្មោះ [redacted] រឿន បានសម្រុះសម្រួលគ្នា ដោយឯកភាពប្រគល់ចំណែកដីកសិកម្មចំនួនពាក់កណ្តាលទៅឱ្យឈ្មោះ [redacted] នី, ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] សារ៉ែក ។ ប៉ុន្តែ ការព្រមព្រៀងនេះ គឺភាគីទាំងសងខាងមិនបានធ្វើជាលិខិតយថាភូត ស្របតាមមាត្រា៣៣៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនោះទេ ។



Scanned with CamScanner

១.ឃ. តាមសំអាងហេតុនៅក្នុងចំណុច (១.គ) ខាងលើ ឃើញថាសកម្មភាពព្រមព្រៀងរបស់ដើមចោទ និងសហចុងចម្លើយ គឺផ្ទុយទៅនឹងទម្រង់ដែលទាមទារឱ្យមានដោយក្រមរដ្ឋប្បវេណី តាមបញ្ញត្តិមាត្រា៣៣៦ កថាខណ្ឌទី២ ។ ហេតុនេះ គប្បីតុលាការទទួលស្គាល់ពីការអះអាងនូវមោឃភាពនៃកំណត់ហេតុខាងលើ របស់ដើមចោទ តាមបញ្ញត្តិមាត្រា៣៥៧ នៃក្រមរដ្ឋប្បវេណី ។

**២. ចំពោះការទាមទារឱ្យទទួលស្គាល់ដើមចោទជាម្ចាស់កម្មសិទ្ធិ តុលាការយល់ឃើញថា៖**

២.ក. ដើមចោទឈ្មោះ [redacted] ជុន បានថ្លែងការណ៍ថា៖ រដ្ឋបានចែកដីឱ្យខ្លួន០២កន្លែង គឺដីឡូតិ៍ផ្ទះមួយកន្លែង និងដីកសិកម្មមួយកន្លែង ហើយបន្ទាប់ពីបានដីកសិកម្មនោះមក ខ្លួនបានកាប់ឆ្ការអាស្រ័យផលនៅលើដីនោះ និងបានទៅស្នើសុំធ្វើប្លង់កម្មសិទ្ធិផងដែរ ។ ចំពោះលោក [redacted] ហៃ ជាមេធាវីតំណាងឱ្យដើមចោទ ក៏បានបន្ថែមទៀតថា៖ ចំពោះដីនេះ គេចែកឱ្យកូនក្ដីរបស់ខ្លួន ដោយហេតុថា គាត់ជាប្រជាពលរដ្ឋក្រីក្រ មានប័ណ្ណក្រីក្រ ម្យ៉ាងទៀត នៅក្នុងប័ណ្ណចាប់ឆ្នោត និងប័ណ្ណសម្គាល់កម្មសិទ្ធិ គឺពុំមានបញ្ជាក់ថា ជាទ្រព្យសម្បត្តិរួមប្ដីប្រពន្ធទេ ដោយដីនោះ គឺមានតែឈ្មោះ [redacted] ជុន តែប៉ុណ្ណោះ ។ រីឯសហចុងចម្លើយឈ្មោះ [redacted] វឿន បានថ្លែងការណ៍ថា៖ ចំពោះដីសម្បទានសង្គមកិច្ចនេះ គឺជាដីរដ្ឋដែលចែកឱ្យពលរដ្ឋក្រីក្រមានកូនច្រើន ដោយកាលនោះ លោក [redacted] ជុន ជាមេគ្រួសារជាអ្នកចាប់ឆ្នោត គឺគេឱ្យតែមេគ្រួសារជាអ្នកចាប់ឆ្នោតប៉ុណ្ណោះ ។ ចំណែកសហចុងចម្លើយឈ្មោះ [redacted] ធី, ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] សារ៉េត បានថ្លែងការណ៍ថា៖ ការដាក់ពាក្យស្នើសុំដីនេះ គឺឪពុកម្ដាយរបស់ពួកខ្លួនជាអ្នកដាក់ពាក្យស្នើសុំរួមជាមួយគ្នា ។ ចំពោះលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយបានបញ្ជាក់បន្ថែមថា៖ កូនក្ដីខ្លួនឈ្មោះ [redacted] វឿន និងឈ្មោះ [redacted] ជុន បានដាក់ពាក្យស្នើសុំរួមគ្នាតាមរយៈគោលនយោបាយសម្បទានសង្គមកិច្ច ដោយកាលនោះកូនក្ដីខ្លួនបានទទួលដីពីរឡូតិ៍ជាប់គ្នា ដោយដាក់តែឈ្មោះ [redacted] ជុន ទេដែលជាមេគ្រួសារ ហើយអំឡុងពេលធ្វើប្លង់ទទួលដីនោះ គឺកូនក្ដីខ្លួនពុំទាន់លែងលះគ្នាឡើយ ។

២.ខ. នាពេលទាញហេតុផលដោយផ្ទាល់មាត់ សាក្សីឈ្មោះ [redacted] សុវណ្ណ បានអះអាងថា៖ ចំពោះដីនោះ គឺជាដីសម្បទានដែលរដ្ឋចែកឱ្យគ្រួសារក្រីក្រ ហើយការបែងចែកដីនេះធ្វើតាមរយៈការចាប់ឆ្នោត ដោយមេគ្រួសារជាអ្នកចាប់ឆ្នោត ។

២.គ. តាមការពិនិត្យទៅលើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៤០៧០១០៩-០៣២៦ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ បានបញ្ជាក់ថា ដើមចោទឈ្មោះ [redacted] ជុន គឺជាម្ចាស់កម្មសិទ្ធិលើដីទំហំ ១០០០០ ម២ (មួយម៉ឺន) ម៉ែត្រការ៉េ មានទីតាំងនៅភូមិគិរីអភិវឌ្ឍន៍ ឃុំឈានឡើង ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។ ម្យ៉ាងទៀត តាមប័ណ្ណសន្លឹកឆ្នោតដីឡូតិ៍លំនៅដ្ឋាន និងដីឡូតិ៍កសិកម្មចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ បានបញ្ជាក់ថា អ្នកដែលទទួលនូវដីកសិកម្មទំហំ១ ហិចតានោះ គឺជាដើមចោទឈ្មោះ [redacted] ជុន ។

២.ឃ. តាមរយៈការអះអាងរបស់ភាគីដើមចោទក្នុងចំណុច (២.ក) និងភស្តុតាងក្នុងចំណុច (២.គ) ខាងលើ ឃើញថា មានភាពស៊ីសង្វាក់គ្នាដែលអាចបញ្ជាក់បានថា ដើមចោទឈ្មោះ [redacted] ជុន គឺមានចំណែកទាំងមូលនៅលើដីកសិកម្មទំហំ ១០០០០ ម២ (មួយម៉ឺន) ម៉ែត្រការ៉េ មានទីតាំងនៅភូមិគិរីអភិវឌ្ឍន៍ ឃុំឈានឡើង ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ពិតមែន ។ ដោយឡែក ចំពោះការអះអាងរបស់ភាគីសហចុងចម្លើយ

នៅក្នុងចំណុច (២.ក) និងការអះអាងរបស់សាក្សីនៅក្នុងចំណុច (២.ខ) ខាងលើនេះវិញ ឃើញថា ពុំមានភាពស៊ីសង្វាក់គ្នាទៅនឹងភស្តុតាង ដែលអាចឲ្យតុលាការជឿជាក់ទៅតាមការអះអាងរបស់ភាគីសហចុងចម្លើយ នោះទេ ។

២.ង. តាមសំអាងហេតុក្នុងចំណុច (២.ឃ) ខាងលើ ឃើញថា ដើមចោទឈ្មោះ [redacted] ជុន គឺជាម្ចាស់កម្មសិទ្ធិលើដីទំហំ ១០០០០ ម² (មួយម៉ឺន) ម៉ែត្រការ៉េ មានទីតាំងនៅភូមិគិរីអភិវឌ្ឍន៍ ឃុំឈានឡើង ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ប្រាកដមែន ។ ហេតុនេះ គប្បីតុលាការទទួលស្គាល់ដើមចោទឈ្មោះ ឆាយ ជុន ជាម្ចាស់កម្មសិទ្ធិលើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៤០៧០១០៩-០៣២៦ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ ដែលមានទីតាំងស្ថិតនៅភូមិគិរីអភិវឌ្ឍន៍ ឃុំឈានឡើង ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។

៣. ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្តី តុលាការយល់ឃើញថា៖

តាមបញ្ញត្តិមាត្រា៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីដែលចាញ់ក្តី ។ ហេតុនេះ គប្បីតុលាការសម្រេចឲ្យសហចុងចម្លើយ ជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

## សេចក្តីសម្រេចបញ្ចប់

១. បញ្ជាក់ថា កំណត់ហេតុចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ រវាងឈ្មោះ [redacted] ជុន និងឈ្មោះ [redacted] រឿន ត្រូវមោឃភាព ។

២. ទទួលស្គាល់ឈ្មោះ [redacted] ជុន ជាម្ចាស់កម្មសិទ្ធិលើដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៤០៧០១០៩-០៣២៦ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ ដែលមានទីតាំងស្ថិតនៅភូមិគិរីអភិវឌ្ឍន៍ ឃុំឈានឡើង ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

សាលក្រមនេះ ត្រូវបានប្រកាសនៅក្នុងសាលសវនាការជាសាធារណៈនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ ។ ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ នៅក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
កំពង់ឆ្នាំង, ថ្ងៃទី...ខែ...ឆ្នាំ...
ក្រឡាបញ្ជី
[redacted]

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ខេត្តកំពង់ឆ្នាំង, ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២
ចៅក្រម
ហត្ថលេខា និង ត្រា
[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ១៥កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ខេត្តកំពង់ឆ្នាំង, ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២
ក្រឡាបញ្ជី
[redacted]

បានឃើញ
ចៅក្រម
[redacted]